# មហាព្រះវេស្សន្តរជាតក (សង្ខេប)

## កណ្ឌសក្កបព៌ (ទី១០)

លំដាប់នោះ ក្នុងកាលរាត្រីកន្លងទៅហើយ ព្រះអាទិត្យក៏រះឡើង សក្កៈទេវរាជទ្រង់ចុះមកបំពេញទានបារមីនៃព្រះពោធិសត្វឲ្យកាន់តែជាតិយោភាពឡើងទៀត ទ្រង់ក្លែងភេទជាព្រាហ្មណ៍ចាស់ជរាចូលទៅក្រាបថ្វាយបង្គំសំណេះសំណាលសាកសួរសុខទុក្ខ រួចតាជីទូលពណ៌នានូវក្ដីលំបាកតោកយ៉ាករបស់គាត់ថាគ្មានភរិយាសោះ ទើបគាត់ក្រាបបង្គំទូលសុំព្រះនាងមទ្រី។ ព្រះបាទស្រីវេស្សន្តរ ឥតមានព្រះរាជហឫទ័យរុញរាទេ ប៉ុន្តែទ្រង់មានព្រះចិន្តាព្រួយបារម្ភខ្លាចក្រែងព្រះអគ្គមហេសីពុំព្រម ទើបទ្រង់ផ្ទៀងព្រះនេត្រទតទៅទឹកព្រះភ័ក្ត្រព្រះនាង។ ព្រះនាងមទ្រីទ្រង់បានជ្រាបព្រះអធ្យាស្រ័យទើបក្រាបបង្គំទូលថាៈ "បពិត្រព្រះស្វាមីអើយ! កុំថាឡើងត្រឹមតែព្រះអង្គដាក់ទានខ្ញុំម្ចាស់នេះដល់ព្រាហ្មណ៍ចាស់ជរា ប្រសិនបើព្រាហ្មណ៍នេះប្រាថ្នាសាច់ថ្លើមដង្ហើមប្រមាត់ សូមព្រះអង្គយកព្រះខ័នកាត់ខ្ញុំមទ្រីបំពេញទានបារមីចុះ ឬមួយបើព្រាហ្មណ៍នេះចង់បាននូវទ្រព្យធនអ្វី សូមព្រះអង្គយកខ្ញុំមទ្រីទៅលក់យកទ្រព្យដាក់ទានដល់ព្រាហ្មណ៍ស្នមតាមព្រះរាជសទ្ធាចុះ ខ្ញុំមទ្រីស្ម័គ្រចិត្តជួយបំពេញទានបារមីរបស់ព្រះអង្គឥតប្រកែកឡើយ"។ ព្រះអង្គក៏ប្រទានព្រះនាងមទ្រីដល់ឥន្ទព្រាហ្មណ៍នោះ។ កាលនោះ ផែនដីកម្រើកជាលើកទី៦។

ចំណែកឥន្ទព្រាហ្មណ៍ កាលបានទទួលព្រះរាជទានព្រះនាង មទ្រីហើយក៏មានចិត្តសោមនស្សយ៉ាងក្រៃលែងហើយក្រាបបង្គំទូលសរសើរនូវព្រះហឫទ័យដ៏សប្បុរសអស្ចារ្យនៃព្រះក្សត្រាក្សត្រីទាំងពីរព្រះអង្គ។ ក្នុងខណៈនោះឥន្ទព្រាហ្មណ៍បានក្លែងភេទជាទិព្វដ៏វិចិត្ររុងរឿងមួយរំពេច ហើយទ្រង់បានប្រគល់ថ្វាយនូវព្រះនាងមទ្រីដល់ព្រះបាទស្រីវេស្សន្តរវិញ ហើយថានឹងប្រទានព្រះពរដល់ព្រះអង្គ។ ព្រះវេស្សន្តរបានសូមព្រះពរអំពីព្រះឥន្ទធិរាជ៨ប្រការគឺៈ

ទី១ សូមឲ្យព្រះវររាជបិតា ស្ដេចមកនាំយកយើងខ្ញុំត្រឡប់ទៅព្រះនគរវិញ។

អត្ថបទដោយ៖ មាស សុភាព

ទី២ សូមឲ្យយើងមានអំណាច អាចដោះទុក្ខទោសរបស់សត្វទាំងឡាយឲ្យផុតពីសេចក្ដីស្លាប់។

ទី៣ សូមឲ្យបានជួយសង្គ្រោះដល់ជនកំសត់ទុគ៌តទូទៅឲ្យផុតក្ដីលំបាកតោកយ៉ាក។

ទី៤ សូមកុំឲ្យយើងខ្ញុំមានចិត្តត្រេកត្រអាលក្នុងផ្លូវកាមគុណជាអកុសល។

ទី៥ សូមឲ្យចៅជាលី និងនាងក្រឹស្នា បានគ្រប់គ្រងបុរីពិជ័យជេតុត្តរ។

ទី៦ កាលបើយើងខ្ញុំបានទៅដល់បុរីរាជធានីហើយ សូមឲ្យមានអាហារទិព្វកើតឡើងរៀងរាល់ថ្ងៃ។

ទី៧ សូមឲ្យការបរិច្ចាគទានរបស់យើងខ្ញុំ កុំបីមានខ្វះកន្ទះអ្វីឡើយ។

ទី៨ ក្រោកការរំលាយបញ្ចក្ខន្ធហើយ សូមឲ្យយើងខ្ញុំបាន ទៅកើតក្នុងឋានតុសិតទេវលោក កុំបីខានឡើយ។

ព្រះឥន្ទ្រាធិរាជបានប្រសិទ្ធីពរទាំង៨ប្រការ ថ្វាយព្រះវេស្សន្តរ និងព្រះនាងមទ្រីហើយ ក៏ទៅកាន់ឋានត្រៃត្រឹង្សសួគ៌នាយវិញហោង។

(ចប់ កណ្ឌទី១០ កណ្ឌកសក្កបាព៌ សូមរង់ចាំតាមដានកណ្ឌទី១១ នៅសប្ដាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព